ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

Kingdom of Wonder

feel the warmth

ក្រសួងទេសចរណ៍

លេខ ៤១៤ សណ.កហ

# សេចក្តីជូនដំណឹង

## ស្តីពី

## លេខទំនាក់ទំនងបន្ទាន់សម្រាប់ភ្ញៀវទេសចរក្នុងពេលទស្សនាព្រះរាជាណាចក្រកម្ពុជា

លេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេស(គ.អ.ច.ទ)មានកិត្តិយសសូមជម្រាបជូនប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ឱ្យបានជ្រាបសារជាថ្មីថា៖ ដើម្បីរួមគ្នាលើកកម្ពស់កិត្តិនាមព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាព ទំនុកចិត្ត និងភាពកក់ក្តៅសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ គ.អ.ច.ទ. និងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធបាននិងកំពុងយកចិត្តទុកដាក់ក្នុងការពង្រឹងកិច្ចសហការក្នុងការផ្តល់សេវាជំនួយនិងដោះស្រាយបញ្ហាជូនភ្ញៀវទេសចរប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាពស្របតាមអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»។

ករណីភ្ញៀវទេសចរជាតិ និងអន្តរជាតិជួបប្រទះបញ្ហាចៃដន្យ ឬត្រូវការជំនួយបន្ទាន់ក្នុងអំឡុងពេលស្នាក់នៅ និងធ្វើដំណើរទេសចរណ៍នៅកម្ពុជា សូមទំនាក់ទំនងលេខប្រតិកម្មរហ័សប្រចាំការ ២៤ម៉ោង ដូចខាងក្រោម៖

១. ករណីពាក់ព័ន្ធនឹងនីតិវិធីចូល-ចេញប្រទេសកម្ពុជា ៖

– អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ៖ ០៦៨ ៣៨៦ ៦៩៩/០៧៨ ៣៨៦ ៦៩៩/០៨៧ ៣៨៦ ៦៩៩

២. ករណីសន្តិសុខ និងសុវត្ថិភាព ៖

– អគ្គស្នងការដ្ឋាននគរបាលជាតិ ៖ ១១៧

– នាយកដ្ឋាននគរបាលទេសចរណ៍ ៖ ០១៦ ៦៥៤ ៧៣៦

– ក្រុមប្រតិកម្មរហ័សសម្រាប់ជនបរទេស៖ ០៣១ ២០១ ២៣៤៥/០៣១ ៦០១ ២៣៤៥

៣. ករណីគ្រោះថ្នាក់ដល់រាងកាយ ឬត្រូវការជំនួយផ្នែកសុខភាពបន្ទាន់ ៖

– រថយន្តសង្គ្រោះបន្ទាន់ ៖ ១១៩

ករណីត្រូវការជំនួយបន្ទាន់ សូមទំនាក់ទំនងមកកាន់លេខទូរសព្ទទៅតាមប្រភេទករណីដែលបានបញ្ជាក់ជូនខាងលើ ដើម្បីទទួលបានការជួយសង្គ្រោះ និងអន្តរាគមន៍បានទាន់ពេលវេលា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ប្រតិបត្តិករទេសចរណ៍ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមផ្សព្វផ្សាយព័ត៌មាននេះឱ្យបានទូលំទូលាយ។

ថ្ងៃ ចន្ទ ១២កើត ខែ ចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២៦

ក្រសួងទេសចរណ៍

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website: www.tourism.gov.kh
Telegram: t.me/motgovkh
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨៩ ៨៩៨
E-mail: admin@tourism.gov.kh